មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៥៨ អនក្រ.បក
## ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់
## ក្រសួងធនធានទឹក និង ឧតុនិយម

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

មាត្រា ១ ._ អនុក្រឹត្យនេះកំណត់បេសកកម្ម និង រៀបចំបណ្តាអង្គភាព នៃក្រសួងធនធានទឹកឧតុនិយម និងមុខការនៃបណ្តាអគ្គនាយកដ្ឋាន និង នាយកដ្ឋាននានា ។

www.pheakdeylaw.com

## ជំពូកទី២
## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា ២ .**_ ក្រសួងធនធានទឹក និងឧតុនិយម ត្រូវបានរាជរដ្ឋាភិបាលប្រគល់ភារកិច្ចឲ្យដឹកនាំ និងគ្រប់គ្រងលើវិស័យធនធានទឹក និងឧតុនិយម នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣ .**_ ក្រសួងធនធានទឹក និង ឧតុនិយម មានមុខងារ និង ភារកិច្ច ដូចតទៅ ÷

-កំណត់គោលនយោបាយ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានទឹក បំរើឲ្យការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងការថែរក្សាការពារប្រកបដោយនិរន្តរភាព ជាលក្ខណៈជាតិ និងអន្តរជាតិស្រប តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

-សិក្សាស្រាវជ្រាវ នូវសណ្ឋានពលទឹក រួមទាំងលើដី ទាំងក្រោមដី និងធាតុអាកាសក្នុងក្របខ័ណ្ឌជាតិ និង អន្តរជាតិ ដើម្បីបង្កើតឡើងនូវមូលដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រច្បាស់លាស់ ។

-លើកទិសដៅ ផែនការរយៈពេលខ្លី មធ្យម និងវែង ក្នុងការធ្វើអាជីវកម្ម ការអភិវឌ្ឍន៍ និងថែរក្សាការពារនូវធនធានទឹក និង ឧតុនិយម ដើម្បីបំរើឲ្យសេដ្ឋកិច្ចជាតិ ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ទាំងទីក្រុង ទាំងនៅជនបទ ។

-គ្រប់គ្រង ត្រួតពិនិត្យនូវរាល់ការធ្វើអាជីវកម្ម លើធនធានទឹកដោយផ្ទាល់ និងប្រយោលប្រកបដោយសិទ្ធិភាព និងកាត់បន្ថយឲ្យបានជាអតិបរមានូវគ្រោះមហន្តរាយ ដែលអាចកើតមានឡើង ។

-រៀបចំតាក់តែងច្បាប់ លិខិតបទដ្ឋាន និងបទបញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធ នឹងការគ្រប់គ្រងធនធានទឹក ព្រមទាំងតាមដានលើការអនុវត្តន៍ ។

-ប្រមូលចងក្រងឯកសារ និង ធ្វើអាជីវកម្មនូវទិន្នន័យឧតុនិយម និង ជលសាស្ត្រ បំរើ ឲ្យដល់វិស័យនានាដែលមានការពាក់ព័ន្ធជាលក្ខណៈជាតិ និង អន្តរជាតិ ដើម្បីផលប្រយោជន៍សង្គមជាតិទាំងមូល ។

-ផ្តល់ការគាំទ្រ និង ការណែនាំបច្ចេកទេសជាចាំបាច់ដល់ម៉ែនជិន អង្គការវិជ្ជាជីវៈសហគមន៍ និងប្រជាពលរដ្ឋជាទូទៅដែលមានការពាក់ព័ន្ធ ដើម្បីកែលំអ និងធ្វើអាជីវកម្មធនធានទឹកឲ្យបានសមស្រប ។

-ពង្រីក និងបញ្ចូលនូវបច្ចេកវិទ្យាទំនើបៗ ដើម្បីមានវិធានការបណ្តុះបណ្តាល កែលំអ និង ផ្សព្វផ្សាយ ។

-ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាតិ និងការងារសហប្រតិបត្តិការអន្តរជាតិ លើវិស័យធនធានទឹក និង ឧតុនិយម ។

-ចូលរួមអនុវត្ត ការងារពាក់ព័ន្ធនឹងអាងទន្លេមេគង្គ ស្របតាមភារកិច្ចរបស់ក្រសួង ។

www.pheakdeylaw.com

មាត្រា ៤ ._ ក្រសួងធនធានទឹក និង ឧតុនិយម មានរចនាសម្ព័ន្ធ ដូចតទៅ ៖

ក- អង្គភាពថ្នាក់កណ្តាល ៖

-អគ្គាធិការដ្ឋាន

-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល

-អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស

-ខុទ្ទកាល័យរដ្ឋមន្ត្រី

ខ- អង្គភាពមូលដ្ឋាន ៖

-មន្ទីរធនធានទឹក និង ឧតុនិយម ខេត្ត ក្រុង និងរាជធានី ។

អង្គការលេខរបស់ក្រសួងធនធានទឹក ឧតុនិយម ជា ឧបសម្ពន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូកទី ៣

## អគ្គាធិការដ្ឋាន

មាត្រា ៥ ._ អគ្គាធិការដ្ឋាន ទទួលបន្ទុក ៖

-ធ្វើអធិការកិច្ចជាប្រចាំ ទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងធនធានទឹក និងឧតុនិយម ។

-ធ្វើរបាយការណ៍ ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ចរួចហើយ និង ពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។

-ប្រតិបត្តិភារកិច្ច តាមការដែលរដ្ឋម ន្ត្រីបានប្រគល់ទំនុកចិត្ត ។

អគ្គាធិការដ្ឋាន ដឹកនាំដោយ អគ្គាធិការ មួយរូបនិងអមដោយអគ្គាធិការរងជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៤

## អគ្គនាយកដ្ឋានកិច្ចការ រដ្ឋបាល

មាត្រា ៦ ._ អគ្គនាយកដ្ឋានកិច្ចការ រដ្ឋបាល ទទួលបន្ទុកធ្វើទំនាក់ទំនង សំបុត្រ និងគ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក សម្ភារៈបរិក្ខារ ពលាណេយ្យ ហិរញ្ញកិច្ច ផែនការស្ថិតិ តាមដាននិងវាយតម្លៃការងារ សហប្រតិបត្តិការជាតិ និង អន្តរជាតិ ការងារបណ្តុះបណ្តាលធនធានមនុស្ស ។

អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល ដឹកនាំដោយអគ្គនាយកមួយរូប និង អាចអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។ អគ្គនាយកដ្ឋាននេះមាន នាយកដ្ឋានចំណុះ ចំនួន ៣ ៖

-នាយកដ្ឋាន រដ្ឋបាល និង ធនធានមនុស្ស

-នាយកដ្ឋាន ផែនការ និង សហប្រតិបត្តិការអន្តរជាតិ

-នាយកដ្ឋាន ហិរញ្ញវត្ថុ

www.pheakdeylaw.com

មាត្រា ៧ ._ នាយកដ្ឋាន រដ្ឋបាល និង ធនធានមនុស្ស ទទួលបន្ទុក :

-សំរបសំរួល សកម្មភាពគ្រប់ផ្នែករបស់ក្រសួង នៅថ្នាក់កណ្តាល និង រវាងថ្នាក់កណ្តាលជាមួយ នឹង អង្គភាពមូលដ្ឋានក្រោមឱវាទ ។

- គ្រប់គ្រង និង ចរាចរឯកសាររដ្ឋបាលផ្សេង ៗ របស់ក្រសួង ។

- សរុប និង ធ្វើរបាយការណ៍ការងារ សកម្មភាពផ្សេងៗ របស់ក្រសួង ។

- រៀបចំសៀវភៅ ស្តីពីនីតិវិធីរដ្ឋបាល និង គ្រប់គ្រងបណ្ណាល័យ ។

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការនិងភ្នាក់ងាររាជការរបស់ក្រសួង ដោយរៀបចំទំនាក់ទំនងជាមួយ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។

- រៀបចំលិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព ។

- រៀបចំស្ថិតិលើការ គ្រប់គ្រងបុគ្គលិក និងតារាងពត៌មានប្រតិវត្តិ ។

- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង ។

- រៀបចំការងារ បៀវត្សពលកម្ម ប្រាក់កំរៃ និងរបបធានារ៉ាប់រងសង្គម ។

- កសាងផែនការ បណ្តុះបណ្តាលមន្ត្រីរាជការរយៈពេលវែង និង ខ្លី ក្នុងប្រទេស និង ក្រៅ ប្រទេស ។

- សហការជាមួយគ្រឹះស្ថានសិក្សាសាធារណៈនានា ដើម្បីចូលរួមកសាងកម្មវិធីសិក្សា និង សកម្មភាពរបស់អង្គភាពទាំងនោះ សំរាប់បណ្តុះបណ្តាលស្របទៅតាមតម្រូវការអភិវឌ្ឍន៍ នៃ សង្គម ។

- លើកសំណើបង្កើត ឬរំសាយអង្គភាពនានា រៀបចំតួនាទីភារកិច្ចកែសំរួលរចនាសម្ព័ន្ធតាម ស្ថានភាពជាក់ស្តែង តាមការប្រគល់ភារកិច្ចរបស់ប្រធានស្ថាប័ន ។

មាត្រា ៨ ._ នាយកដ្ឋាន ផែនការ និង សហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុក :

-រៀបចំចងក្រង គ្រប់គ្រងប្រព័ន្ធទិន្នន័យ ស្ថិតិរបស់ក្រសួង និងលើកផែនការអភិវឌ្ឍន៍ជាប្រចាំ រយៈពេលខ្លី មធ្យម និង វែង លើគ្រប់ផ្នែកទាំងអស់ ។

-រៀបចំ កសាងកម្មវិធីវិនិយោគសាធារណៈ កម្មវិធីចំណាយសាធារណៈ និង កម្មវិធីអភិវឌ្ឍន៍ គោលដៅអាទិភាពរបស់ក្រសួង ។

-ធ្វើកម្មវិធីសហប្រតិបត្តិការក្នុង និងក្រៅប្រទេស លើវិស័យអភិវឌ្ឍន៍ធនធានទឹក និង ឧតុនិយម។

-សំរបសំរួល ជំនួយពីបរទេស និងត្រួតពិនិត្យការអនុវត្តន៍ ។

www.pheakdeylaw.com

-ស្វែងរកកិច្ចព្រមព្រៀង ឬពិធីសារនៃកិច្ចសហប្រតិបត្តិការ របស់ក្រសួងធនធានទឹក និងឧតុនិយម ជាមួយអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ។

មាត្រា៩._ នាយកដ្ឋានហិរញ្ញវត្ថុ ទទួលបន្ទុក ៖

-ប្រមូលផ្តុំតម្រូវការ លើកគម្រោងថវិកាក្រសួង ធ្វើកម្មវិធីចំណាយឆ្នាំ និងតាមដានរំលឹកពីការ ប្រតិបត្តិ។

-គ្រប់គ្រងប្រព័ន្ធថវិកា និងភារកិច្ចគណនេយ្យរបស់ក្រសួង ។

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ។

-ធ្វើកម្មវិធីចំណាយ និង បែងចែកប្រេង ឥន្ធនៈ គ្រឿងបន្លាស់ សំភារៈបរិក្ខាររដ្ឋបាល ដែលប្រើប្រាស់ ជូនក្រសួង ។

-បង្កើត និងបែងចែកបៀវត្ស ជូនមន្ត្រីបុគ្គលិក អង្គភាពក្រោមឱវាទក្រសួង ។

-កាន់បញ្ជីសាច់ប្រាក់នូវសាលាប័ត្រ និងគណនេយ្យរបស់ក្រសួង ។

-គ្រប់គ្រងពត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។

-ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ ។

-គ្រប់គ្រងបន្ទុកគណនី របស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ ។

-ប្រមូលចំណូល ដោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ បញ្ចូលថវិការដ្ឋ ។

ជំពូកទី ៥

អគ្គនាយកដ្ឋានកិច្ចការ បច្ចេកទេស

មាត្រា ១០._ អគ្គនាយកដ្ឋានកិច្ចការ បច្ចេកទេស ទទួលបន្ទុកគ្រប់គ្រងធ្វើអាជីវកម្ម ត្រួតពិនិត្យ ដែលនាំឲ្យប្រើប្រាស់ ថែរក្សា និងធ្វើឲ្យកាន់តែសំរបសំរួល នូវរាល់ការងារដែលពាក់ព័ន្ធនឹងទឹកទាំងលើដី ទាំងក្រោមដី និង អាកាសធាតុ ។ អគ្គនាយកដ្ឋានកិច្ចការបច្ចេកទេសដឹកនាំដោយអគ្គនាយកម្នាក់ ដែលអាចមានអគ្គនាយករងជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋាននេះ មាននាយកដ្ឋានចំណុះចំនួន ៦ ៖

-នាយកដ្ឋាន គ្រប់គ្រង និង អភិរក្សធនធានទឹក

-នាយកដ្ឋាន ជលសាស្ត្រ និង ការងារទន្លេ

-នាយកដ្ឋាន ឧតុនិយម

-នាយកដ្ឋាន ធារាសាស្ត្រកសិកម្ម

-នាយកដ្ឋាន ទឹកស្អាត និង អនាម័យ

-នាយកដ្ឋានវិស្វកម្ម

មាត្រា ១១._ នាយកដ្ឋាន គ្រប់គ្រង និង អភិរក្សធនធានទឹក ទទួលបន្ទុក ៖

-សិក្សា កសាង និង អនុវត្តគំរោងផែនការជាយុទ្ធសាស្ត្រ របស់កិច្ចអភិវឌ្ឍន៍ ពហុបំណង ៖ វារីអគ្គិសនី ត្រួតពិនិត្យជំនន់ ស្រោចស្រព....។ល។ លើកលែងតែគំរោងណាដែលប្រើ ទឹកសំរាប់ផលិតអគ្គិសនី ជាបំណងចំបង ។

www.pheakdeylaw.com

-គ្រប់គ្រងតំបន់ផ្ទៃរងទឹកភ្លៀង និង កសាងកម្មវិធី ចាត់ចែងប្រើប្រាស់ទឹក ដើម្បីធានាផលប្រយោជន៍ការធ្វើអាជីវកម្ម និង អភិរក្សធនធានទឹក ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព ។

-ស្រាវជ្រាវកសាងគោលនយោបាយច្បាប់ បទបញ្ញត្តិ និងគោលការណ៍ណែនាំផ្សេងៗ ដើម្បីឲ្យដំណើរការអភិរក្សធនធានទឹកប្រកបដោយនិរន្តរភាពជូនរាជរដ្ឋាភិបាលពិនិត្យសម្រេច និងធ្វើការណែនាំផ្សព្វផ្សាយ ត្រួតពិនិត្យលើការអនុវត្តន៍ ។

-ធ្វើអធិការកិច្ចបច្ចេកទេស លើហេដ្ឋារចនាសម្ព័ន្ធដែលពាក់ព័ន្ធនឹងធនធានទឹក ។

-ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រ ដើម្បីមានវិធានការកែលម្អ ផ្សព្វផ្សាយ និង ចងក្រង ឯកសារបច្ចេកទេស ដើម្បីបំរើដល់ការអភិវឌ្ឍន៍ ។

មាត្រា ១២ ._ នាយកដ្ឋាន ជលសាស្ត្រ និង ការងារទន្លេទទួលបន្ទុក ។

-រៀបចំកសាងគំរោង តំឡើងស្ថានីយ៍ជលសាស្ត្រលើទីតាំងប្រភពទឹកសំខាន់ៗបំរើ ឲ្យដំណើរការអភិវឌ្ឍន៍វិស័យធនធានទឹក ។

-រៀបចំកសាងគំរោងផែនការ រយៈពេលខ្លី មធ្យម និង វែង លើការងារការពារ ការហូរច្រោះកំណេកដី និង ច្រាំងទន្លេ ។

-ធ្វើការស្រាវជ្រាវតាមដាន នូវរាល់របបជលសាស្ត្រទាំងលើដី ទាំងក្រោមដី ដោយគ្រប់គ្រងតម្លើងស្ថានីយ៍ជលសាស្ត្រ ប្រមូលវិភាគទិន្នន័យ បំរើដល់វិស័យនានា ។

-អនុវត្តការងារវាស់កំពស់ទឹក ធារទឹក កករទឹក ។

-អនុវត្តលើការពិនិត្យគុណភាពទឹក នៅតាមស្ថានីយ៍ជលសាស្ត្រសំខាន់ៗ ។

-សិក្សាស្រាវជ្រាវបាតុភូតជលសាស្ត្រ គំរូជលសាស្ត្រ ជលគណនា និង សក្តានុពលទឹកលើដី និងក្រោមដី ។

-គ្រប់គ្រង និងផ្លាស់ប្តូរពត៌មានជលសាស្ត្រ ព្រមទាំងធ្វើការព្យាករណ៍ និង ជូនដំណឹងជាមុននូវគ្រោះទឹកជំនន់ កង្វះខាតទឹក ដែលអាចកើតមានឡើង ដើម្បីមានវិធានការទាន់ពេលវេលា ។

-រៀបចំប្រព័ន្ធពត៌មានភូមិសាស្ត្រ ដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍន៍ នៃវិស័យធនធានទឹក ។

មាត្រា ១៣ ._ នាយកដ្ឋាន ឧតុនិយម ទទួលបន្ទុក ៖

-រៀបចំកសាងគំរោងផែនការរយៈពេលខ្លី មធ្យម និង វែង បំរើដល់ការស្តារ និងអភិវឌ្ឍន៍ វិស័យឧតុនិយម ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

-តម្លើង និង គ្រប់គ្រងស្ថានីយ៍ឧតុនិយមក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

-ធ្វើការសង្កេតតាមដាន នូវអាកាសធាតុទាំងលើផ្ទៃដី ទាំងក្នុងលំហអាកាស សំដៅបំរើឲ្យដល់គ្រប់វិស័យដែលពាក់ព័ន្ធ ។

-ប្រមូល និង ផ្លាស់ប្តូរទិន្នន័យ ឧតុនិយមក្នុង និងក្រៅប្រទេស ដើម្បីធ្វើការវិភាគកសាងឯកសារមូលដ្ឋាន ។

-ធ្វើការព្យាករណ៍រយៈពេលខ្លី វែង សំរាប់តម្រូវការរបស់ស្ថាប័ននានា និងជូនដំណឹងជាមុននូវគ្រោះធម្មជាតិ ដែលអាចកើតមានឡើងជាយថាហេតុ ដើម្បីមានវិធានការទាន់ពេលវេលា ។

www.pheakdeylaw.com

-ធ្វើការផ្លាស់ប្តូរ និងស្រាវជ្រាវបច្ចេកវិទ្យាទំនើបៗ នៃវិស័យឧតុនិយមក្នុងក្របខ័ណ្ឌជាតិ និង អន្តរជាតិ ។

-រៀបចំរបាយការណ៍ប្រចាំថ្ងៃ ស្តីពីស្ថានភាពឧតុនិយម នៅព្រះរាជាណាចក្រកម្ពុជា និង របាយការណ៍ផ្សេងៗទៀតដែលចាំបាច់សំរាប់រាជរដ្ឋាភិបាល ក្នុងការបំពេញភារកិច្ច និងទទួលខុសត្រូវដែលពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀង និងអនុសញ្ញាអន្តរជាតិ ។

-ត្រូវអនុវត្តនិងសំរបសំរួលកិច្ចសហប្រតិបត្តិការ ដើម្បីការអភិវឌ្ឍវិស័យឧតុនិយមកម្ពុជាជាមួយភ្នាក់ងារសហប្រជាជាតិ អង្គការឧតុនិយមនៃពិភពលោក ព្រមទាំងធ្វើក្នុងនាមជាតំណាងអចិន្ត្រៃយ៍ នៃអង្គការឧតុនិយមពិភពលោកប្រចាំនៅកម្ពុជា ។

មាត្រា ១៤ ._ នាយកដ្ឋាន ធារាសាស្ត្រកសិកម្ម ទទួលបន្ទុក :

-រៀបចំគំរោងផែនការរយៈពេលខ្លី មធ្យម និង វែង សំរាប់ការស្តារនិងអភិវឌ្ឍប្រព័ន្ធ ធារាសាស្ត្រ តូច មធ្យម និង ធំ ។

-ចាត់ចែងគ្រប់គ្រងលើកិច្ចដំណើរការ និង ថែទាំភាពគង់វង្សប្រព័ន្ធធារាសាស្ត្រ និង ប្រព័ន្ធរំដោះទឹកដែលមានស្រាប់ ។

-គ្រប់គ្រង ត្រួតពិនិត្យ និង វាយតំលៃលទ្ធផលប្រចាំឆ្នាំនូវសកម្មភាពធ្វើអាជីវកម្មទឹកក្រោមដីបំរើ ឲ្យដល់ការផ្គត់ផ្គង់ធារាកសិកម្ម ។

-រៀបចំគំរោងផែនការអភិវឌ្ឍន៍តំបន់ការពារទឹកប្រៃ នៅតំបន់ឆ្នេរសមុទ្រ ។

-ចាត់ចែងគ្រប់គ្រងលើកិច្ចដំណើរការ និង ថែទាំ ភាពស្ថិតស្ថេរនៃអាងទឹក អាងស្តុកទឹកប្រភេទធំ និង មធ្យម ។

-បំផុសអោយមានក្រុមនិងសមាគមសហគមន៍កសិករ ប្រើប្រាស់ទឹក និងតាមដានការអនុវត្តន៍ជាប្រចាំ ។

-ចាត់ចែង ត្រួតពិនិត្យនិងដឹកនាំការងារអន្តរាគមន៍ បង្ការបន្ធូរបន្ថយគ្រោះមហន្តរាយបណ្តាលមកពីទឹកជំនន់ និង រាំងស្ងួត ។

មាត្រា ១៥ ._ នាយកដ្ឋានទឹកស្អាត និង អនាម័យទទួលបន្ទុក :

-ធ្វើការសិក្សាប្រភពទឹកលើដី និង ទឹកក្រោមដី ។

-ធ្វើការសិក្សាស្រាវជ្រាវ វាយតម្លៃ ព្រមទាំងរៀបចំគំរោង ផែនការរយៈពេលខ្លី មធ្យម វែង លើការស្តារអភិវឌ្ឍន៍ នូវប្រភពទឹកដែលបំរើដល់ការផលិតទឹកស្អាត និងតាមដានព្រមទាំងត្រួតពិនិត្យការអនុវត្តន៍ ។

-រៀបចំគំរោងផែនការរយៈពេលខ្លី មធ្យម វែង លើការអភិវឌ្ឍន៍ បញ្ចេញទឹកសំណល់ពីរាជធានី ទីក្រុង ទីប្រជុំជន និង គ្រប់គ្រងតាមដាន ព្រមទាំងត្រួតពិនិត្យ ការអនុវត្តន៍ ។

-ធ្វើការសិក្សា ស្រាវជ្រាវ និងតាមដានវាយតម្លៃជាប្រចាំ នូវគុណភាពទឹកប្រភពទឹកលើដី និង ក្រោមដី ដែលបាននិងកំពុងយកមកប្រើប្រាស់ ។

www.pheakdeylaw.com

មាត្រា ១៦ ._ នាយកដ្ឋានវិស្វកម្មធារាសាស្ត្រ មានភារកិច្ច ៖

-សិក្សា គ្រោងប្លង់ និងគាំពារត្រួតពិនិត្យគាំទ្រនូវរាល់ប្រភេទសំណង់ ដែលមានការពាក់ព័ន្ធនឹងធនធានទឹក ។

-គ្រប់គ្រងឧបករណ៍ និងគ្រឿងចក្រដែលបំរើអោយដល់ការសិក្សាគ្រោងប្លង់និងគាំពារសំណង់ ។

-អនុវត្តលើការពិនិត្យគុណភាពដី បំរើដល់ការសាងសង់ ។

-សិក្សានិងស្រាវជ្រាវ នូវគំរូសំណង់ បទដ្ឋានសំណង់ និង បច្ចេកវិទ្យាទំនើបៗ ដែលបំរើឲ្យដល់សេដ្ឋកិច្ចជាតិ និង ធានានិរន្តរភាពក្នុងការប្រើប្រាស់ ។

## ជំពូកទី ៦

## ខុទ្ទកាល័យរដ្ឋមន្ត្រី

មាត្រា ១៧ ._ ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលបានកំណត់តាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ដូចមានចែងក្នុងមូលបទខាងលើស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី ៧

## អង្គភាពមូលដ្ឋាន

មាត្រា ១៨ ._ នៅតាមខេត្ត ក្រុងនីមួយៗមានមន្ទីរធនធានទឹក និង ឧតុនិយម ខេត្ត ក្រុង និង រាជធានីដែលទទួលបន្ទុកអនុវត្ត និង សំរបសំរួលសកម្មភាពរបស់ក្រសួង ។

## ជំពូកទី ៨

## អវសានបញ្ញត្តិ

មាត្រា ១៩ ._ ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង នៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ។

មាត្រា ២០ ._ ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ ប្រធានស្ថាប័ន នៃស្ថាប័នដទៃទាំងនោះ និង រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម ត្រូវសហការគ្នា ដើម្បីបែងចែកការងារទទួលខុសត្រូវ និង អនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួមរបស់ រដ្ឋមន្ត្រីក្រសួងធនធានទឹក និង ឧតុនិយម និងប្រធានស្ថាប័នទាំងនោះ ។

មាត្រា ២១ ._ បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២២ ._ ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

www.pheakdeylaw.com

មាត្រា ២៣ ._ អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

ហត្ថលេខា

លឹម គានហោ



# អង្គការលេខរបស់ក្រសួងធនធានទឹកនិងឧតុនិយម

